**ប្រការ៣** : នាយកខុទ្ទកាល័យ ប្រធានអធិការកិច្ច នាយកដ្ឋានប្រៃណីយ៍ នាយកដ្ឋានផែនការគណនេយ្យ និង ហិរញ្ញកិច្ច នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិនិង អង្គការ AICF/USA- CAMBODIA ត្រូវអនុវត្តតាមប្រកាសនេះ ។

**ប្រការ៤** : ប្រកាសនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**សូ ឃុន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ ០២ ឆ្នាំ ១៩៩៦

**ប្រកាសលេខ : ០២០ បទ.ប្រក**

**ស្តីពីការកំណត់បេឡាវងជូនមន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ ក្រុងព្រះសីហនុ**

* * *

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មិនា ឆ្នាំ ១៩៨៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីវិស័យប្រៃសណីយ៍ និង ទូរគមនាគមន៍
- ពិនិត្យសំណូមពរចាំបាច់ ស្តីពីការរីកចំរើន នៃការងារប្រៃសណីយ៍ និង ទូរគមនាគមន៍ ។

**សំរេច**

**ប្រការ១** : ត្រូវបានកំណត់បេឡាវងបណ្តោះអាសន្នជូនមន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ក្រុង ព្រះសីហនុ ជាតែមប្រៃសណីយ៍ ដែលមានតម្លៃស្មើនឹងប្រាក់ចំនួនប្រាំបួនរយពាន់រៀលគត់ ( ៩០០.០០០ រៀល ) ។

**ប្រការ២** : រាល់សេចក្តីសំរេចឬប្រកាសទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៣** : នាយកខុទ្ទកាល័យ លោកប្រធានអធិការកិច្ច លោកនាយកដ្ឋានចំណុះក្រសួង និង លោក ប្រធានមន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ខេត្តសៀមរាប ត្រូវទទួលបន្ទុកអនុវត្តន៍តាមខ្លឹមសារនៃប្រកាសនេះ យោងតាមលិខិតស្នើសុំរបស់បជិគ្គាហកៈមន្ទីរ ប.ទ ក្រុងព្រះសីហនុ ។

**ប្រការ៤** : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**សូ ឃុន**

* * *